ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូអញ្ជើញទៅចូលរួម និងធ្វើជាសហប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី៣ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤ ដល់ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុងដាលី ខេត្តយូណាន ប្រទេសចិន តាមការអញ្ជើញរបស់ឯកឧត្តម វ៉ាង យី(Wang Yi) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន ។

កិច្ចប្រជុំនេះ នឹងផ្តល់នូវកាលានុវត្តភាពដ៏ល្អ ក្នុងការលើកកំពស់ និងពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ និងមិត្តភាពដែលមានស្រាប់ នៅក្នុងក្របខ័ណ្ឌមេគង្គ-ឡានឆាង ក៏ដូចជាធ្វើការពិភាក្សាអំពីការត្រៀមរៀបចំកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី២ ដែលនឹងប្រព្រឹត្តទៅនៅកម្ពុជា នាខែមករា ឆ្នាំ២០១៨។

នៅក្នុងកិច្ចប្រជុំនេះ ក៏រំពឹងនឹងមានការអនុម័តលើឯកសារសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាង លើកទី៣
- បញ្ជីគម្រោងដែលឧបត្ថម្ភដោយមូលនិធិពិសេសរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង សម្រាប់ឆ្នាំ២០១៧ និង
- ខ្សែទូរស័ព្ទបន្ទាន់នៃលេខាធិការដ្ឋានជាតិ និងក្រុមសម្របសម្រួលរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ។

នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន នឹងអញ្ជើញចូលរួមក្នុងពិធីតាំងពិព័រណ៍រូបថតស្តីពីសមិទ្ធិផលនានានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់គេហទំព័រផ្លូវការ នៃលេខាធិការដ្ឋានកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងចិន ព្រមទាំងអញ្ជើញធ្វើសន្និសិទកាសែតរួមគ្នាដោយសហប្រធានទាំងពីរ ជាមួយឯកឧត្តម វ៉ាង យី។

គួរកត់សំគាល់ថា ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំលើកទី១របស់រដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងជិនហុង ខេត្តយូណាន ប្រទេសចិន ដោយឈរលើគោលការណ៍កុងសង់ស៊ីស ការបើកចំហរ បរិយាប័ន្ន សមភាព ការពិគ្រោះយោបល់ និងសម្របសម្រួលទៅវិញទៅមក ការស្ម័គ្រចិត្ត ការរួមចំណែករួម និងផលប្រយោជន៍រួមគ្នា និងការគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិនានា ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh